# ការដាំដុះដំណាំចំរុះ

## INTER CROPPING



លោក ពិន វណ្ណារ៉ូ

# សេចក្ដីផ្ដើម

- ការដាំដំណាំចំរុះ គឺជាការដាំដំណាំលើសពីមួយមុខនៅពេលជាមួយគ្នា ក្នុងដីស្រែ ឬ ចំការតែមួយ ។
- ដោយសារការដាំដុះដំណាំចំរុះនេះ អ្នកនឹងទទួលផលបានច្រើនមុខ លើស ពីអ្នកដាំដំណាំតែមួយមុខគត់ ។
- មួយចំណែកទៀត អ្នកអាចបន្ថយនូវការបំផ្លាញរបស់ដំណាំពីពពួកស្មៅ សត្វល្អិត និង ជំងឺទាំងឡាយផង ។

# គុណសម្បត្តិនៃការដាំដុះដំណាំចំរុះ

- រក្សាគុណភាពដី និង ការពារដីពីការហូរច្រោះ ។
- ប្រើប្រាស់អោយអស់នូវលទ្ធភាពពន្លឺថ្ងៃ និង ចំណីអាហាររបស់រុក្ខជាតិ ។
- ជួយការពារផលដំណាំអោយផុតពីការខាតបង់ទាំងស្រុង ព្រោះសត្វល្អិត ស្មៅ និង ជំងឺ ភាគច្រើនរាតត្បាតលើដំណាំតែមួយប្រភេទប៉ុណ្ណោះ ។
- ជួយអោយយើងទទួលបាននូវផលិតផលកសិកម្ម និង ស្បៀងបានច្រើន ដោយប្រើពលកម្ម ដដែលលើផ្ទៃដីមួយកន្លែងដូចគ្នា ។

# គុណសម្បត្តិនៃការដាំដុះដំណាំចំរុះ

- ផ្គត់ផ្គង់ដល់គ្រួសារនូវម្ហូបអាហារគ្រប់គ្រាន់ និង ប្លែក ៗ ដូចជា

  - ដាំសណ្តែកមួយរងនៅចន្លោះពោត និង ដំឡូងមី ។

  - សណ្តែកអង្គុយ សណ្តែកទ្រើង នៅចន្លោះត្រប់ ត្រសក់ ឬ ពពាយ ។

  - ដាំត្រប់ ត្រសក់ ឬ ពបាយ និង សណ្តែកអង្រែ នៅពេលជាមួយគ្នា ។

នៅពេលបេះ ត្រសក់ ត្រប់ ឬ ពពាយ រួចត្រូវដាំសណ្តែកអង្គុយ ពោត ឬ សណែកទ្រើង។

ក្រោយមកយើងអាចប្រមូលផលដំណាំទាំងនេះដំណាលសណ្តែកអង្រែដែរ ។

# គុណសម្បត្តិនៃការដាំដុះដំណាំចំរុះ

- យើងអាចដាំរុក្ខជាតិផ្ទើជីស្រស់ និង ដំណាំស្ល្បៀងជាមួយគ្នា ។
- ដាំសណ្តែកអង្គុយជាមួយពោត ពេលប្រមូលផលពោត និង សណ្តែករួច យើងត្រូវកាប់ ឬ ភ្ជួរដើមសណ្តែកលប់ចូលទៅក្នុងដី ។
- ពពួកសណ្តែក គឺជារុក្ខជាតិដែលបន្ថែមអាសូត វាជាអាហារដ៏សំខាន់របស់រុក្ខជាតិទៅក្នុងដីតាមរយៈឫសរបស់វា ។ នៅពេលដែលយើងដាំពពួកសណ្តែកចំរុះជាមួយដំណាំដទៃៗទៀត អាសូតនឹងត្រូវបានបង្កើននៅក្នុងដី សំរាប់អោយដំណាំលើកក្រោយអាចស្រូប ឬ បឺតយកបាន ។

# គុណវិបត្តិនៃការដាំដុះដំណាំចំរុះ

- ត្រូវធ្វើការជ្រើសរើសមុខដំណាំដោយប្រុងប្រយ័ត្ន ដោយមិនអោយដំណាំមួយបឺតយក ជីជាតិទឹក ឬ ទទួលនូវពន្លឺថ្ងៃច្រើនជាងដំណាំមួយទៀតឡើយ ។

- ពូជដំណាំថ្មី ជាច្រើនដែលផ្តល់ទិន្នផលខ្ពស់ មិនអាចដុះបានល្អជាមួយដំណាំប្រភេទផ្សេងគ្នាទេ ។

- ប្រសិនបើយើងដាំពោតតែមួយមុខ   យើងនឹងទទួលបាននូវផលច្រើនជាងដាំលាយជាមួយសណ្តែក ប៉ុន្តែបើយើងដាំពោតលាយជាមួយសណ្តែក នោះយើងនឹងទទួលបាននូវអាហារច្រើនមុខ ។



ដាំពោតតែមួយមុខ



ដាំពោតចំរុះសណ្ដែក

# ការដាំដុះរាយប៉ាយ Mixed Intercropping

- ធ្វើការសំអាតដីរបស់យើងអោយបានស្អាតល្អ រួចពង្រាយគ្រាប់ដំណាំផ្សេងៗ ទៅក្នុងដីនោះ ។



# ការដាំដុះចំរុះជួរ Row Intercropping

- ដាំដុះដំណាំ ២ មុខ ឬ ច្រើនប្រភេទតែម្តងជាជួរ ឬ គុម្ពចន្លោះគ្នា ។

ឧទាហរណ៍ ដាំពោតមួយជួរ រួចដាំសណ្តែកមួយជួរ បន្ទាប់មកពោតមួយជួរទៀត ធ្វើបែបនេះ រហូតដល់ពេលដីរបស់អ្នក ។



# ការដាំដុះឆ្លាស់ជួរ Strip Intercropping

- ដាំដំណាំមួយមុខច្រើនជួរ ជិតដំណាំមួយមុខទៀត ។
  ឧទាហរណ៍ ៖ ដាំពោត ៤ ជួរ បន្ទាប់មកដាំសណ្ដែកអង្គុយ ២ ជួរ រួចដាំពោត
  ៤ ជួរទៀត ធ្វើរបៀបនេះទាល់តែពេញដី ។
  ចំណាំ៖ ត្រូវដាំដំណាំដែលយើងត្រូវការវា
  ច្រើនជាងគេ ធ្វើយ៉ាងណាអោយច្រើន
  ជាងដំណាំផ្សេងៗទៀត ។



# ការដាំដុះដំណាំការពារ Alley cropping

- ដាំដើមឈើមួយជួរ រួចដាំដុះដំណាំស្បៀងច្រើនជួរ បន្ទាប់មកដាំដើមឈើមួយជួរទៀតធ្វើរបៀបនេះទាល់តែពេញចំការ ។



- ដើមឈើនឹងជួយការពារដំណាំស្បៀងពីខ្យល់បក់ខ្លាំង និង ជីជាតិពីស្រទាប់ក្រោមដីមកកាន់ផ្នែកខាងលើ ផ្តល់អោយដំណាំយើងផង ។

# ការដាំដុះបន្តក្នុងដីដែលបានដាំហើយ Relay cropping



# កំណត់ចំណាំ Note

- បើសិនដីរបស់យើងស្ថិតនៅលើទួល  ត្រូវដាំតាមទទឹងរង  ហើយមិនត្រូវដាំតាមបណ្តោយពីលើចុះក្រោមទេ។ គេហៅការដាំរបៀបនេះថា ការដាំជារង្វង់ ហើយវានឹងជួយបន្ថយនូវការហូរច្រោះដី

